**Declassified to Public**
**09 June 2021**

លេខ / No: D31

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស.**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

| | |
|---|---|
| ចំពោះមុខ ៖ | **ចៅក្រម យូ ប៊ុនឡេង** |
| | **ចៅក្រម Laurent KASPER-ANSERMET** |
| កាលបរិច្ឆេទ ៖ | ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ |
| ភាសា ៖ | អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ ៖ | សម្ងាត់ |

# ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ
# វិធាន ២១.១ឃ

<u>សហព្រះរាជអាជ្ញា</u>
លោកស្រី ជា លាង
លោក Andrew CAYLEY

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
23 / 03 / 2012
ម៉ោង (Time/Heure) : 9:30 AM
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé

០០៣/០៧-០៩-២០០៩/អ.វ.ត.ក./ក.ស.ច.ស. លេខ/No: D31

យើង **Laurent Kasper-Ansermet** សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

**ជូនដំណឹងដល់**

លោក **ស៊្វ ម៉េត (ហៅ ម៉េត ហៅ សំរេច)** សញ្ជាតិខ្មែរ កើតនៅថ្ងៃ ខែ ឆ្នាំ មិនដឹង បច្ចុប្បន្នប្រហែលរស់នៅក្នុងក្រុងបាត់ដំបង ឬនៅស្រុកសំឡូត ខេត្តបាត់ដំបង (ប្រទេសកម្ពុជា) ឲ្យបានជ្រាបថា៖

១. លោក ត្រូវបានជាប់ឈ្មោះថាជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរកំពុងបន្តដំណើរការដោយយោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទិននឹងការធ្វើផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ ឬការប្រព្រឹត្តជាបុគ្គល ឬដោយចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ចំពោះបទឧក្រិដ្ឋខាងក្រោមដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក៖

ក. អំពើឃាតកម្ម ការសម្លាប់បំផុតពូជ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ ពូជសាសន៍ ឬសាសនា ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងត្រូវផ្តន្ទាសទោសតាមមាត្រា ៥, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

ខ. ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់ ការលុបបំបាត់ដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងទៀងទាត់របស់ឈ្លើយសង្គ្រាម និងជនស៊ីវិល អំពើអមនុស្សធម៌ និងការបង្កដោយចេតនាឲ្យមានការរងទុក្ខវេទនាឈឺចាប់ដ៏ធំធេង ឬឲ្យមានរបួសស្នាមធ្ងន់ធ្ងរដល់រូបរាងកាយ ឬសុខភាព អំពើទារុណកម្ម និងអំពើមនុស្សឃាត ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានៃទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៦, ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

គ. អំពើមនុស្សឃាត និងអំពើទារុណកម្ម ជាការរំលោភបំពានទៅលើក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ (មាត្រា៥០០, ៥០១, ៥០៣, ៥០៤, ៥០៥, ៥០៦, ៥០៧, និង ៥០៨) ដែលត្រូវផ្តន្ទាទោសតាមមាត្រា៣(ថ្មី), ២៩(ថ្មី) និង ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

ដោយផ្អែកលើមូលដ្ឋាននៃបទល្មើសដែលបានប្រព្រឹត្តឡើងរវាងឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ នៅក្នុងប្រទេសកម្ពុជា ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ម្នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង/ឬជាបុគ្គល

ម្នាក់ដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានលើកឡើងខាងលើ ក្នុងតួនាទីរបស់លោកជាលេខាកងពល ៥០២ នៃកងទ័ពបដិវត្តកម្ពុជា ពីខែ មិថុនា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩ និងជាសមាជិកគណៈកម្មាធិការជំនួយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា។ ជនរងគ្រោះដែលមានចំនួនដ៏ច្រើនបញ្ជាក់ពីលក្ខណៈធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលលោកត្រូវបានចោទប្រកាន់។

២. ការចោទប្រកាន់ទាំងនេះគឺផ្អែកលើមូលដ្ឋានទាំងអង្គហេតុដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញា និងអង្គហេតុដែលត្រូវបានរកឃើញនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ។

៣. ដោយអនុលោមតាមច្បាប់ លោកត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់លោកមិនទាន់ត្រូវបានរកឃើញ ហើយយើងនៅតែអាចរង់ចាំស្តាប់ចម្លើយភស្តុតាងពីលោក ទាក់ទងនឹងការចោទប្រកាន់ទាំងនេះប្រសិនបើលោកមានបំណងផ្តល់ភស្តុតាងបែបនេះ។

៤. ដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក [វិធាន ២១(១)(ឃ)] សិទ្ធិ និងការធានានៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងឋានៈជាជនសង្ស័យ រួមមាន សិទ្ធិមានមេធាវីការពារខ្លួនតាមការជ្រើសរើសរបស់ខ្លួន សិទ្ធិមានលទ្ធភាពទទួលបានឯកសារសំណុំរឿង (អនុវត្តស្របដៀងគ្នាតាមវិធាន ៥៥(៦) វិធាន ៥៥(១) និងវិធាន ៥៨ លើកលែងតែបញ្ញត្តិនៃវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក) និងសិទ្ធិនៅស្ងៀមមិនឆ្លើយតបនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី។

៥. ជាការចាំបាច់ យើងសូមណែនាំដល់លោក ទៅធ្វើការទាក់ទងជាមួយផ្នែកគាំពារការការពារក្តីនៃ អ.វ.ត.ក ដែលមានមុខងារផ្តល់ជូនលោកនូវជំនួយក្នុងការរៀបចំចាត់ចែងមេធាវីការពារសម្រាប់លោក។ ផ្នែកគាំពារការការពារក្តី ក៏អាចផ្តល់ជូនលោកផងដែរនូវបញ្ជីឈ្មោះមេធាវី ដែលអាចរកបានសម្រាប់ជនគ្រប់រូបដែលមានសិទ្ធិទទួលបានជំនួយផ្នែកច្បាប់នៅចំពោះមុខ អ.វ.ត.ក។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១២

**សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ**

**Co-juge d'instruction international réserve**

**International Reserve Co- Investigating Judge**

**Laurent Kasper-Ansermet**